# ផូស៊ីលឈើតាមដងទន្លេមេគង្គ

អ្វីទៅជាផូស៊ីលឈើ? ផូស៊ីលឈើ Petrified Wood មានន័យថាឈើក្លាយជាថ្មៗ[១] វាកើតឡើងនៅពេលរុក្ខជាតិត្រូវបានកប់ដោយដីល្បាប់ និងការពារពីការពុកផុយដោយសារតែអុកស៊ីសែន និងសារជាតុសរីរាង្គនានា។ បន្ទាប់មកទឹកក្រោមដីដែលសំបូរទៅដោយសារជាតុរំលាយឆ្លងកាត់ដីល្បាប់ដោយជំនួសវត្ថុធាតុដើមរុក្ខជាតិដើមជាមួយស៊ីលីកា កាល់ស៊ីត ឬសារជាតុខនិចផ្សេងៗ ពេលខ្លះក៏មានឥទ្ធិពលពីភ្នំភ្លើង។

តាមរយៈការចុះសិក្សា និងពិនិត្យផូស៊ីលឈើតាមដងទន្លេមេគង្គនៅទីតាំងមួយចំនួនក្នុងខេត្តស្ទឹងត្រែងឆ្នាំ២០១៩ និងខេត្តក្រចេះឆ្នាំ២០២៣ របស់ក្រុមការងារសិក្សាស្រាវជ្រាវផូស៊ីលនៃនាយកដ្ឋានតំបន់បេតិកភណ្ឌ នៃក្រសួងបរិស្ថាន យើងបានប្រទះឃើញផូស៊ីលឈើជាច្រើននៅតំបន់នេះ។ បើយោងលើផែនទីភូគព្ភសាស្រ្តនៃព្រះរាជាណាចក្រកម្ពុជាត្រង់ចំណុចសំគាល់ T3-J2ss[២] (រូបលេខ១) ចន្លោះពីទីរួមខេត្តស្ទឹងត្រែងមកកាន់ទីរួមខេត្តក្រចេះ ដីមួយភាគធំជាទីតាំងសំបូរទៅដោយពពួកថ្មភក់ ថ្មស្រទាប់ ចុងសម័យកាល Triassic និងពាក់កណ្តាលសម័យ Jurassic (អាយុកាលប្រហាក់ប្រហែល ២៣៥លានឆ្នាំមក ១៦៣.៥លានឆ្នាំ)។[៣] លើសពីនេះ នៅផ្នែកខាងក្រោមព្រំប្រទល់ខេត្តស្ទឹងត្រែងមកកាន់ទីរួមខេត្តក្រចេះ ផ្ទៃដីមួយផ្នែកធំប្រទះឃើញពពួកថ្មភក់ Siltstone, Shale, Marl ថ្មទាំងនេះស្ថិតនៅក្នុងសម័យកាល Triassic (អាយុកាលប្រមាណ ២៥២-២០១លានឆ្នាំ)។ ផ្នែកខ្លះនៅខាងកើតជាប់ដងទន្លេមេគង្គ (ត្រង់ចំណុចសំគាល់ Q2a) ក៏មានពពួកថ្មភក់ អាយុកាលប្រមាណ៨០ម៉ឺនឆ្នាំ និងចំណុចចខ្លះ (ត្រង់ចំណុចសំគាល់ N2-Q1) មានអាយុកាលប្រមាណ៥លានឆ្នាំ នេះបើយោងលើផែនទីភូគព្ភសាស្រ្តនៃព្រះរាជាណាចក្រកម្ពុជា។ ទាំងនេះជាព័ត៌មានបឋមដែលបង្ហាញតាមរយៈផែនទីភូគព្ភសាស្រ្ត។

---

[១] www.wikipedia.org

[២] General Department of Mineral Resource, 2010, Geological Map of Cambodia

[៣] INTERNATIONAL CHRONOSTRATIGRAPHIC CHART, 2012

អត្ថបទដោយៈ លឹម វណ្ណច័ន្ទ

## អត្ថបទ៖ ផូស៊ីលឈើតាមដងទន្លេមេគង្គ

នៅក្នុងភូមិសាស្ត្រឃុំស្រែក្រសាំង ស្រុកសៀមបូក ខេត្តស្ទឹងត្រែង មានវត្តមាននៃផូស៊ីលឈើជាច្រើន ខ្លះមានទំហំធំ ដែលកប់នៅក្នុងដីប្រមាណ១ទៅ២ម៉ែត្រ(រូបលេខ២២)។ ផូស៊ីលឈើនេះ ស្ថិតនៅស្រទាប់ផ្នែកខាងលើ ដែលមានដីឥដ្ឋលាយជាមួយក្រួសអាចម៍ផ្កាយ (រូបលេខ២៣)។ តាមរយៈព័ត៌មានដែលបានទទួលពីប្រជាជនតាមដងទន្លេមេគង្គក្នុងតំបន់នោះ គេបានប្រទះថ្មគគីរ (ផូស៊ីលឈើ) បាក់ចូលទៅក្នុងទន្លេទាំងដើមៗផងដែរ។ នៅផ្នែកម្ខាងទៀតក្នុងភូមិសាស្ត្រដែនជម្រកសត្វព្រៃ «ព្រៃឡង់» ភូមិសាស្ត្រខេត្តស្ទឹងត្រែង ក៏បានជួបផូស៊ីលឈើក្នុងអូរ ជម្រៅប្រមាណ២-៣ម៉ែត្រ ដែលនៅចម្ងាយប្រមាណ១០គីឡូម៉ែត្រពីដងទន្លេមេគង្គ (រូបលេខ២៤)។ ផូស៊ីលទាំងនេះបានជួបប្រទះស្រទាប់ដីដែលលាយឡំនឹងក្រួសអាចម៍ផ្កាយនេះផងដែរ។

នៅក្នុង២០២៣នេះក្រុមការងារបានចុះសិក្សានៅក្នុងភូមិសាស្ត្រខេត្តក្រចេះ ដូចជានៅទួលចំបក់ក្នុងដែនជម្រកសត្វព្រៃ «ព្រៃឡង់» ស្ថិតក្នុងស្រុកសំបូរ ចម្ងាយ១៥គីឡូម៉ែត្រពីទន្លេមេគង្គដោយរកឃើញបំណែកផូស៊ីលឈើតូចៗជាច្រើន លាយឡំនឹងក្រួសអាចម៍ផ្កាយ ស្រទាប់នេះស្ថិតផ្នែកខាងលើស្រទាប់ថ្មភក់ (រូបលេខ២៥)។ ទីតាំងមួយទៀតស្ថិតនៅខាងកើតទន្លេមេគង្គ ហៅថាទួលស្នាក់ការសំបូរ ក្នុងដែនជម្រកសត្វព្រៃសំបូរ ស្រុកកោះញៀងសែនជ័យក៏មានលក្ខណៈដូចគ្នានឹងទួលចំបក់ដែរ (រូបលេខ២៦) ដោយបានរកឃើញបំណែកផូស៊ីលឈើតូចៗជាច្រើន។ មួយកន្លែងទៀតហៅថាទួលក្រួសអាចម៍ផ្កាយក្បែរសាលាឃុំព្រែកប្រសប់ ស្រុកព្រែកប្រសប់ ក្បែរទីរួមខេត្តក្រចេះ។ ទីតាំងមានក្រួសមានជាច្រើន ខ្លះបានកកជាថ្មផ្ទាំងធំ តែបំណែកនៃផូស៊ីលឈើហាក់ដូចជាមានចំនួនតិច។ ក្រួសអាចម៍ផ្កាយមួយចំនួនក៏ជាផូស៊ីលឈើផងដែរ ត្រង់ចំនុចនេះមានន័យថាផូស៊ីលឈើមួយចំនួននោះ ប្រហែលធ្លាក់រមោលតាមទឹក និងកើតទៅជាក្រួសអាចម៍ផ្កាយ(រូបលេខ២៧)។

តាមរយៈភស្តុតាងមួយចំនួនដែលយើងបានសិក្សា អាចបង្ហាញថាបាតុភូតក្រួសអាចម៍ដូចគ្នា ស្រទាប់ដីដែលមានផូស៊ីលឈើស្ថិតនៅក្នុងស្រទាប់តែមួយ បាតុភូតនេះកើតឡើង

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

ដោយកំលាំងទឹកហូរខ្លាំងក្នុងពេលណាមួយ? ដែលគ្របតណ្តប់លើផ្ទៃដីមួយផ្នែកនៅក្នុងខេត្តស្ទឹងត្រែង និងក្រចេះ។ ផូស៊ីលឈើដែលរកឃើញនៅក្នុងខេត្តស្ទឹងត្រែងមានទំហំធំបន្តមកក្នុងខេត្តក្រចេះ ស្រុកសំបូរ និងស្រុកកោះត្រៀងសែនជ័យមានទំហំតូច និងច្រើនចំណែកនៅត្រង់ចំណុចស្រុកព្រែកប្រសប់មានផូស៊ីលឈើតូចហើយចំនួតិច។ ទាំងនេះវាបានប្រែប្រួលនៃតាមកំលាំងនៃទឹកហូរ ពីខាងលើនៃដងទន្លេមេគង្គ បន្តមកផ្នែកខាងក្រោមក្នុងខេត្តក្រចេះ។ នេះជាទិន្នន័យផ្នែកខ្លះនៃខេត្តស្ទឹងត្រែង និងផ្នែកខ្លះនៃខេត្តក្រចេះប៉ុណ្ណោះ។ ចំពោះទីតាំងនៅក្នុងខេត្តស្ទឹងត្រែង ជាតំបន់ដីគោក ដែលត្រូវបានចាក់បង្គរក្រួសអាចម៍ផ្កាយគ្របលើដើមឈើទាំងនោះ ហើយក្រោយមកបានក្លាយជាផូស៊ីលឈើ។ ចំពោះអាយុកាលនៃផូស៊ីលឈើទាំងឡាយនេះ ស្ថិតនៅផ្នែកខាងលើនៃស្រទាប់ថ្ម សម័យកាល Triassic និងពាក់កណ្តាលសម័យ Jurassic (អាយុកាលប្រហាក់ប្រហែល ២៣៩លានឆ្នាំមក ១៦៣.៥លានឆ្នាំ) ស្រទាប់ខ្លះនៃដីចាក់បង្គរខ្លះអាចមានអាយុកាលថ្មី ចន្លោះ៨០ម៉ឺនឆ្នាំ៕

អត្ថបទដោយ៖ លឹម វណ្ណចន្ទ




រូបលេខ១៖ ផែនទីភូគព្ភសាស្ត្រព្រះរាជាណាចក្រកម្ពុជា



រូបលេខ២៖ ផូស៊ីលឈើ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ៣៖ ស្រទាប់ដីលាយក្រួសអាចម៍ផ្កាយ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង



រូបលេខ៤៖ ផូស៊ីលឈើ ព្រៃឡង់ ខេត្តស្ទឹងត្រែង

អត្ថបទដោយ៖ លឹម វណ្ណចន្ទ




រូបលេខ៥៖ ផូស៊ីលឈើ ទួលចំបក់ ព្រៃឡង់ ខេត្តក្រចេះ



រូបលេខ៦៖ ក្រួសអាចម៍ផ្កាយ ទួលស្នាក់ការសំបូរ ស្រុកកោះក្រៀងសែនជ័យ

អត្ថបទដោយ៖ លឹម វណ្ណចន្ទ



រូបលេខ៧៖ ក្រួសអាចម៍ផ្កាយ ស្រុកព្រែកប្រសព្វ

អត្ថបទដោយ៖ លឹម វណ្ណចន្ទ